**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខៈ ០៤ សរណន

# សារាចរណែនាំ
## ស្តីពី
## ការរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៦

### I. បរិការណ៍នៃការរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុសម្រាប់គ្រប់គ្រងឆ្នាំ ២០០៦

១- ក្នុងឆ្នាំ ២០០៤ កន្លងទៅនេះ ទោះបីជាមានឥទ្ធិពលអវិជ្ជមានខាងក្នុង និង ពីក្រៅមួយចំនួន ដូចជា ការជាប់គាំងខាងនយោបាយ គ្រោះរាំងស្ងួត ការឡើងថ្លៃប្រេងឥន្ធនៈ អំពើភេរវកម្ម ជម្ងឺឧត្បាត យ៉ាងណាក៏ដោយ សេដ្ឋកិច្ចកម្ពុជាសម្រេចបាននូវកំណើនមួយដ៏ខ្ពស់គឺប្រមាណ ៧,៧% ក្នុងថ្លៃថេរ លើស ពីការគ្រោងទុក ៥,៨% ក្នុងច្បាប់ហិរញ្ញវត្ថុ ។ វិស័យទេសចរណ៍ ឧស្សាហកម្មកាត់ដេរ និង សកម្មភាពសំណង់ ដែលបន្តកើនឡើង និង រីកដុះដាលជាលំដាប់ គឺជាកត្តាសំខាន់ក្នុងការជំរុញដល់កំណើននេះ ។ លទ្ធផលនេះ ក៏បានមកផងដែរ ដោយសាររាជរដ្ឋាភិបាលអនុវត្តនូវគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចដ៏ត្រឹមត្រូវ និង គោលនយោបាយសារពើពន្ធប្រកបដោយភាពមោះមុត និង ប្រុងប្រយ័ត្ន គួបផ្សំនឹងគោលនយោបាយរូបិយវត្ថុដ៏សមស្រប ។ អំណោយផលនៃកត្តាខាងក្រៅ ពិសេសគឺការបន្តជួយគាំទ្រពីសំណាក់ដៃគូអភិវឌ្ឍន៍របស់កម្ពុជា ក៏បានរួមចំណែកក្នុងការជំរុញកំណើននេះផងដែរ ។ ទោះជានៅក្នុងបរិការណ៍មួយដែលកម្ពុជាសម្រេចបាននូវកំណើនខ្ពស់ក៏ដោយ ក៏រាជរដ្ឋាភិបាលនៅតែធានាបាននូវស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច ពិសេស រក្សាបាននូវអត្រាអតិផរណាមធ្យមប្រចាំឆ្នាំត្រឹម ៣,៩% គឺទាបជាងគោលដៅដែលបានគ្រោងពីដើមឆ្នាំក្នុងអត្រា ៥% ។ រីឯអត្រាប្តូរប្រាក់មានស្ថិរភាព និយាយជារួម ហើយទុនបំរុងធានាបានសំរាប់ការនាំចូល ៣ ខែ ជាប្រចាំ ។

២- ក្នុងឆ្នាំ ២០០៥ នេះ តាមការព្យាករណ៍ កំណើនសេដ្ឋកិច្ចនឹងសម្រេចបានចំនួន ៦,៣% ដោយសង្ឃឹមថា វិស័យកសិកម្មនឹងកើនឡើងចំនួន ៤,៧% ដែលក្នុងនោះ ផលិតផលស្រូវ និង កសិផល នឹងកើនឡើង ៥,៥% វិស័យឧស្សាហកម្មនឹងកើនឡើងចំនួន ៤,៧% ចំនួនភ្ញៀវទេសចរនឹងកើនឡើង ៣០% សកម្មភាពសាងសង់នឹងកើនឡើង ១៦% ហើយវិស័យសេវាកម្មនឹងកើនឡើង ៧,៨% ។ ប៉ុន្តែការនាំចេញសំលៀកបំពាក់នឹងកើនឡើងប្រមាណតែ ៥% ប៉ុណ្ណោះ ។ ជាសរុប ការនាំចេញនឹងកើនឡើងចំនួន ២៣,៤% ហើយការនាំចូលនឹងកើនឡើង ២៤,៦% ។ ដោយសារវិធានការណ៍របស់រាជរដ្ឋាភិបាល ដែលប្រកាន់យកជំហការងារតាម

អភិក្រមសកម្មគ្រប់គ្រង ស្ថានភាពរូបិយវត្ថុក្នុងឆ្នាំ ២០០៥ នេះ នឹងឆ្លុះបញ្ចាំងផងដែរនូវស្ថានភាពសារពើពន្ធមួយ ដែលមានលក្ខណៈល្អសំរាប់ជំរុញកំណើន និង ការអភិវឌ្ឍន៍ ។ ទុនបម្រុងអន្តរជាតិជារូបិយវត្ថុបរទេស ក៏នឹងបន្តធានាការនាំចូលប្រមាណបាន ៣ ខែ ដែរ ។ អត្រាប្តូរប្រាក់នឹងបន្តរក្សាអោយមានស្ថិរភាព គឺជាមធ្យមភាគក្នុងរង្វង់ប្រមាណ ៤.០៥០ រៀល ក្នុង ១ ដុល្លារអាមេរិក ។

៣- ផ្អែកលើស្ថានភាពគួរអោយលើកទឹកចិត្តនៃសេដ្ឋកិច្ចជាតិនេះ ជាពិសេសលទ្ធផលនៃការអនុវត្តន៍វិធានការកែលំអអភិបាលកិច្ចក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការប្រមូលចំណូលក្នុងត្រីមាសទី ១ ឆ្នាំ ២០០៥ នេះ សម្រេចបានលទ្ធផលគួរកត់សម្គាល់ ជាពិសេស នាយកដ្ឋានពន្ធដារប្រមូលចំណូលបានចំនួន ១៥៥ ពាន់លានរៀល គឺស្មើនឹង ១២៧% នៃការគ្រោងទុក ហើយទីចាត់ការគយនិងរដ្ឋាករប្រមូលចំណូលបានជិត ៣៦៦ ពាន់លានរៀល គឺជិតស្មើនឹង ១១១% នៃការគ្រោងទុក ។ រាជរដ្ឋាភិបាលសង្ឃឹមថា ការអនុវត្តន៍ថវិកាក្នុងឆ្នាំ ២០០៥ នេះ អាចនឹងសម្រេចបានតាមគោលដៅដែលច្បាប់ហិរញ្ញវត្ថុបានកំណត់ ។ ចំណូលថវិកាក្នុងស្រុកអាចនឹងសម្រេចបានចំនួន ១១,៣៨% នៃផសស ធៀបនឹងឆ្នាំ ២០០៤ ដែលសម្រេចបានត្រឹម ១១,២៥% នៃផសស ក្នុងខណៈដែលចំណាយសរុបអាចនឹងសម្រេចបានចំនួន ១៦,៨០% នៃផសស ធៀបនឹងឆ្នាំ ២០០៤ ដែលសម្រេចបានត្រឹម ១៥,៨៧% នៃផសស ហើយក្នុងនោះ ចំណាយចរន្តអាចនឹងសម្រេចបាន ៩,៩០% ដែលអាចធានាបាននូវអតិរេកចរន្តចំនួន ១,៤០% សម្រាប់ប្រើប្រាស់ក្នុងការវិនិយោគ ។ ចំណាយមូលធនសរុបនៃថវិកាអាចនឹងសម្រេចបាន ៦,៩០% នៃផសស នៅក្នុងឆ្នាំ ២០០៥ នេះ ។

៤- ក្នុងឆ្នាំ ២០០៦ កំណើនសេដ្ឋកិច្ចនឹងសម្រេចបានចំនួន ៦,១% ។ ការព្យាករណ៍នេះឈរលើសេណារីយ៉ូសុទិដ្ឋិនិយមដោយសង្ឃឹមថា ការនាំចេញសម្លៀកបំពាក់នឹងកើនឡើងដល់ចំនួន 10% ចំនួនភ្ញៀវទេសចរនឹងកើនឡើង ៣៥% សកម្មភាពសាងសង់នឹងកើនឡើង ២៥% ផលិតផលកសិកម្មនឹងកើនឡើងចំនួន ៧% ។ អត្រាអតិផរណានឹងត្រូវបានគ្រប់គ្រងអោយស្ថិតក្នុងកម្រិតប្រមាណ ៣% ។ ការព្យាករណ៍សំរាប់រយៈពេលមធ្យម (២០០៥-២០០៨) គឺសេដ្ឋកិច្ចនឹងមានកំណើនជាមធ្យមប្រចាំឆ្នាំប្រមាណ ៦% ស្របតាមគោលដៅកំណត់ក្នុងយុទ្ធសាស្ត្រចតុកោណ ទោះបីជាការបញ្ចប់នៃប្រព័ន្ធកូតាអាចធ្វើឱ្យកំណើនវិស័យឧស្សាហកម្មកាត់ដេរធ្លាក់ចុះវិញខ្លះក៏ដោយ ។ រាជរដ្ឋាភិបាលនឹងខិតខំបន្តជំរុញបន្ថែមទៀត លើការអភិវឌ្ឍន៍វិស័យទេសចរណ៍ សកម្មភាពសំណង់ និង សេវាកម្ម ដើម្បីរក្សាអោយមានកំណើនប្រកបដោយចិរភាព ទន្ទឹមនឹងពិពិធកម្មសេដ្ឋកិច្ចពិសេសជំរុញវិស័យកសិកម្ម និង កសិ-ឧស្សាហកម្ម ។ នៅក្នុងឆ្នាំ ២០០៦ នេះ រាជរដ្ឋាភិបាលនឹងបន្តអនុវត្តគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និង គោលនយោបាយសារពើពន្ធប្រកបដោយភាពមោះមុត និង ប្រុងប្រយត្ន័ គួបផ្សំនឹងគោលនយោបាយរូបិយវត្ថុដ៏សមស្រប ដើម្បីធានាសម្រេចឱ្យបាននូវកំណើនសេដ្ឋកិច្ចមួយខ្ពស់ដូចបានកំណត់ខាងលើនេះ ។ រាជរដ្ឋាភិបាល ប្តេជ្ញាបន្តរក្សាស្ថេរភាពម៉ាក្រូសេដ្ឋកិច្ចអោយនៅតែតមតល្អ ពិសេសគ្រប់គ្រងអត្រាអតិផរណាអោយស្ថិតក្នុងកំរិតជាមធ្យមប្រមាណ ៣% ក្នុងមួយឆ្នាំ និង រក្សាអោយបានជារួមនូវលំនឹងនៃអត្រាប្តូរប្រាក់ ។

៥- ពិតណាស់ថា ទោះបីជាកម្ពុជាសម្រេចបាននូវកំណើនសេដ្ឋកិច្ចក្នុងអត្រាមួយយ៉ាងខ្ពស់ ហើយបានខិតខំអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវកម្មវិធីកំណែទម្រង់គ្រប់វិស័យក៏ដោយ ជារួម អត្រានៃភាពក្រីក្រនៅតែមានកម្រិតខ្ពស់នៅឡើយ ដោយសារមូលដ្ឋាននៃកំណើនសេដ្ឋកិច្ចមានលក្ខណៈតូចចង្អៀត ដែលពឹងផ្អែកជាសំខាន់លើកត្តាក្រៅប្រទេស ពិសេសលើការនាំចេញឧស្សាហកម្មកាត់ដេរ និង វិស័យទេសចរណ៍ ។ ដូច្នេះ ដើម្បីធានាបាននូវការចែករំលែកផ្លែផ្កានៃកំណើនសេដ្ឋកិច្ចប្រកបដោយសមធម៌ ដែលនឹងផ្តល់ផលជាវិជ្ជមានដល់ការកាត់បន្ថយភាពក្រីក្រសមស្របតាមគោលដៅអភិវឌ្ឍន៍សហស្សវត្ស រាជរដ្ឋាភិបាលកម្ពុជាប្តេជ្ញាចិត្តអនុវត្តឱ្យបានសម្រេចជោគជ័យនូវ ***«យុទ្ធសាស្ត្រចតុកោណ» ដើម្បីកំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព*** ដែលមានអភិបាលកិច្ចល្អជាស្នូល ដោយផ្តោតលើយុទ្ធសាស្ត្របួនយ៉ាងគឺ៖

*ទី១:* ជំរុញការអភិវឌ្ឍវិស័យកសិកម្ម និង កសិ-ឧស្សាហកម្ម

*ទី២:* ជំរុញការអភិវឌ្ឍវិស័យឯកជន និង បង្កើនការងារ

*ទី៣:* បន្តស្តារ និង កសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និង

*ទី៤:* បន្តជំរុញការកសាងសមត្ថភាពស្ថាប័ន និង ការអភិវឌ្ឍន៍ធនធានមនុស្ស ។

៦- នៅក្នុងក្របខ័ណ្ឌនៃការអនុវត្តន៍យុទ្ធសាស្ត្រនេះ ក្នុងរយៈពេលខ្លីចំពោះមុខ រាជរដ្ឋាភិបាលនឹងបន្តប្រមូលផ្តុំលើកម្មវិធីកំណែទំរង់សំខាន់ៗ ដូចតទៅ÷

*ក.* បន្តអនុវត្តនូវគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចត្រឹមត្រូវ និង ប្រុងប្រយ័ត្ន ដើម្បីជាបរិស្ថានសំរាប់សម្រេចអោយបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ និង ប្រកបដោយចិរភាពក្នុងបរិការណ៍នៃអត្រាអតិផរណាទាប ។

*ខ.* បន្តអនុវត្តនូវកម្មវិធីកំណែទំរង់ហិរញ្ញវត្ថុសាធារណៈ ដែលសំដៅធានានូវភាពទុកចិត្តបាននៃថវិកាជាតិ តាមរយៈការខិតខំបង្កើនចំណូល ការធ្វើវិចារណកម្មចំណាយ ដោយផ្តោតជាពិសេសលើវិធានការពង្រឹងអភិបាលកិច្ចល្អ និង បង្កើនប្រសិទ្ធភាពរបស់រដ្ឋក្នុងការផ្តល់សេវា និង វិធានការកាត់បន្ថយបំណុលជាសាច់ប្រាក់ ដែលរដ្ឋជំពាក់អ្នកផ្គត់ផ្គង់ឯកជន ។

*គ.* បន្តអនុវត្តកំណែទម្រង់រចនាសម្ព័ន្ធ ដើម្បីពង្រឹងបរិស្ថានអំណោយផលសម្រាប់ការអភិវឌ្ឍន៍ផ្នែកឯកជន ជាពិសេសលើកស្ទួយវិស័យកសិកម្ម និង កសិ-ឧស្សាហកម្ម និង ជួយគាំទ្រសហគ្រាសធុនតូច និងមធ្យម ព្រមទាំងជំរុញការសំរួលពាណិជ្ជកម្មតាមរយៈការបង្កើតបញ្ជរតែមួយ និង ជំរុញផ្នែកឯកជនអោយចូលរួមកសាងហេដ្ឋារចនាសម្ព័ន្ធ ដោយមានច្បាប់សម្បទានធានា ក្នុងខណៈដែលរាជរដ្ឋាភិបាលខ្លួនឯងបាន និង កំពុងខិតខំកសាងដោយផ្ទាល់នូវហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ជាពិសេសប្រព័ន្ធស្រោចស្រព ។ ប្រការទាំងនេះទាមទារការពង្រឹងអភិបាលកិច្ចល្អ ពិសេសវិធានការណ៍ប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ការកាត់បន្ថយការិយាធិបតេយ្យ ការអនុវត្តន៍កម្មវិធីសកម្មភាពកំណែទំរង់ច្បាប់ និង តុលាការ ការពង្រឹងនីតិរដ្ឋ និង ការកែលំអទីផ្សារពលកម្ម ។

*ឃ.* បន្តអនុវត្តនូវកំណែទម្រង់ការគ្រប់គ្រងដីធ្លី ដើម្បីជួយគាំទ្រដល់វិស័យកសិកម្មអោយសមស្របតាមច្បាប់ភូមិបាល ដើម្បីឱ្យវិស័យនេះក្លាយទៅជាមូលដ្ឋានរឹងមាំនៃកំណើនសេដ្ឋកិច្ច និង បំពីគោលដៅនៃការកាត់បន្ថយភាពក្រីក្រ ។

*៥.* បន្តពង្រឹងប្រព័ន្ធធនាគារ និង វិស័យធានារ៉ាប់រង និង បន្តអភិវឌ្ឍវិស័យហិរញ្ញវត្ថុទាំងមូល ដើម្បីកៀងគរធនធានហិរញ្ញវត្ថុសម្រាប់ការធ្វើហិរញ្ញប្បទានគម្រោងរបស់ផ្នែកឯកជន ។

*៦.* កសាង និង ពង្រឹងការអនុវត្តន៍ច្បាប់ និង លិខិតបទដ្ឋាននានា ជាពិសេសពង្រឹងរចនាសម្ព័ន្ធស្ថាប័ន និង បំពេញកាតព្វកិច្ចកម្ពុជា ក្នុងឋានៈជាសមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោក ដើម្បីទាញប្រយោជន៍ពីសមាជិកភាពនេះ អោយបានជាអតិបរមា ។

*៧.* បន្តជម្រុញអនុវត្តកំណែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការ, ពិសេសធានាពង្រឹងសមត្ថភាពរដ្ឋបាលបច្ចេកទេស និង ហិរញ្ញវត្ថុ របស់ក្រុមប្រឹក្សាឃុំ-សង្កាត់ សម្រាប់ការអភិវឌ្ឍន៍មូលដ្ឋាន និង ពង្រីកមូលដ្ឋាននៃការគ្រប់គ្រងហិរញ្ញវត្ថុតាមបែបវិសហមជ្ឈការ ពិសេសគឺដើម្បីបម្រើឱ្យគោលការណ៍ «រដ្ឋបាលឯកភាព» ដូចមានកំណត់នៅក្នុងឯកសារក្របខ័ណ្ឌយុទ្ធសាស្ត្រកំណែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការ ។ ក្នុងកម្មវិធីនេះ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវរៀបចំ និង អនុវត្តផែនការបង្កើនប្រសិទ្ធិភាព នៃការផ្ទេរ និង ការផ្តល់ថវិកាជូនមូលនិធិឃុំ-សង្កាត់ រួមមានទាំងលទ្ធភាពនៃការពង្រីកការប្រើប្រាស់ប្រព័ន្ធធនាគារផងដែរ ។ លើសពីនេះទៀត ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវសិក្សាដើម្បីដាក់ឱ្យអនុវត្តសាកល្បងនូវការប្រមូលចំណូលផ្ទាល់ដោយក្រុមប្រឹក្សាឃុំ-សង្កាត់ ជាពិសេសគឺពន្ធប៉ាតង់ និង ពន្ធលើមធ្យោបាយដឹកជញ្ជូននៅរាជធានីភ្នំពេញ និង នៅក្រុងព្រះសីហនុ តែត្រូវស្ថិតក្នុងក្របខ័ណ្ឌច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និង ទ្រព្យសម្បត្តិរបស់ខេត្ត-ក្រុង ។

*៨.* បន្តជម្រុញការអនុវត្តន៍កំណែទម្រង់រដ្ឋបាលសាធារណៈ ពិសេសការពង្រីកការអនុវត្តន៍កន្សោមអាទិភាព និង កម្មវិធីផ្តល់លាភការទៅតាមសមត្ថភាព និង លទ្ធផលការងារ ។

៧- ច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់គ្រប់គ្រងឆ្នាំ ២០០៦ នេះ គឺជាឧបករណ៍ដ៏សំខាន់បំផុតសំរាប់ឈានទៅសម្រេចឱ្យបាននូវបណ្តាគោលដៅជាអាទិភាពខាងលើ ។ នៅក្នុងបរិការណ៍នេះ រាជរដ្ឋាភិបាលមានកាតព្វកិច្ចរៀបចំឱ្យបានទាន់ពេលវេលា នូវសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៦ ។ នៅក្នុងកិច្ចដំណើរការនេះ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវចាប់ផ្តើមការចរចា និង ពិភាក្សារៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៦ ជាមួយក្រសួង-ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុងទាំងអស់ ចាប់ពីថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០០៥ នេះតទៅ រហូតដល់ថ្ងៃទី ៣១ ខែសីហា ឆ្នាំ ២០០៥ ។ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុត្រូវរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុ និង ធ្វើកំណត់បង្ហាញនៃសេចក្តីព្រាងច្បាប់នេះហើយផ្ញើរជូនគណៈរដ្ឋមន្ត្រីអោយបាននៅក្នុងសប្តាហ៍ទី១ នៃខែតុលា ឆ្នាំ ២០០៥ ដើម្បីគណៈរដ្ឋមន្ត្រីពិនិត្យ និង សំរេច ហើយផ្ញើរជូនស្ថាប័ននីតិបញ្ញត្តិ អោយបានក្នុងសប្តាហ៍ទី១ នៃខែ វិច្ឆិកា ២០០៥ ដើម្បីស្ថាប័ននីតិបញ្ញត្តិមានពេលគ្រប់គ្រាន់ ក្នុងការពិនិត្យ ពិភាក្សា និង អនុមតិសេចក្តីព្រាងនេះបានមុនថ្ងៃ ២៥ ខែ ធ្នូ ២០០៥ ។

## II- ក្របខ័ណ្ឌថវិកាជាតិឆ្នាំ ២០០៦

### ២-១. ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចឆ្នាំ ២០០៦

៨- លទ្ធផលអនុវត្តឆ្នាំ ២០០៤ និង ការព្យាករណ៍រយៈពេលមធ្យម បង្ហាញឱ្យឃើញថា ស្ថានភាពម៉ាក្រូសេដ្ឋកិច្ចឆ្នាំ ២០០៦ នឹងមានលក្ខណៈប្រហាក់ប្រហែលដូចឆ្នាំ ២០០៥ ដែរ ហើយសូចនាករម៉ាក្រូសំខាន់ៗ នឹងអាចសម្រេចបានដូចខាងក្រោម ÷

- កំណើនសេដ្ឋកិច្ចតាមថ្លៃថេរ នឹងមានចំនួនប្រមាណ ៦,១% ដែលធ្វើឱ្យផលិតផលសរុបក្នុងស្រុក (ផសស) សំរេចបានប្រមាណ ២៨.២១១ ពាន់លានរៀល ។
- អតិផរណានឹងស្ថិតក្នុងកម្រិតប្រមាណ ៣,៥% ដែលតំរូវអោយមានការបន្តអនុវត្តន៍គោលនយោបាយសារពើពន្ធប្រកបដោយភាពមោះមុត និង ប្រុងប្រយត្ន័ គួបផ្សំនឹងគោលនយោបាយរូបិយវត្ថុដ៏សមស្រប ។
- អត្រាប្តូរប្រាក់រៀល- ដុល្លារជាមធ្យមនឹងស្ថិតក្នុងកំរិត ៤.០៥០ រៀល ក្នុងមួយដុល្លារអាមេរិក ។
- និនភាពគណនីចរន្ត នឹងថយចុះពី ១១% នៃ ផសស ក្នុងឆ្នាំ ២០០៥ ទៅ ១០.៣% នៃ ផសស ក្នុងឆ្នាំ ២០០៦ ។
- ទុនបម្រុងអន្តរជាតិសរុប នឹងបន្តធានាបាននូវការនាំចូលចំនួន ៣ ខែ ។

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានភារកិច្ចសហការជាមួយបណ្តាក្រសួង និង ស្ថាប័នពាក់ព័ន្ធ ដើម្បីតាមដាន និង វាយតម្លៃជាប្រចាំលើស្ថានភាពម៉ាក្រូសេដ្ឋកិច្ចកម្ពុជា ដើម្បីជាមូលដ្ឋានសំរាប់ត្រួតពិនិត្យការអនុវត្តន៍ច្បាប់ហិរញ្ញវត្ថុ ជាពិសេសការត្រួតពិនិត្យពាក់កណ្តាលឆ្នាំ ។

## ២-២. បណ្តាបញ្ហាប្រឈមក្នុងការអនុវត្តន៍ច្បាប់ហិរញ្ញវត្ថុសម្រាប់គ្រប់គ្រងឆ្នាំ ២០០៦

៩- បច្ចុប្បន្ន រាជរដ្ឋាភិបាលកំពុងតែប្រឈមមុខនឹងបញ្ហាមួយចំនួន នៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាពិសេស ភាពចាំបាច់ក្នុងការបង្កើនចំណូលដើម្បីសងបំណុលចាស់ផង និង ដើម្បីបំពេញតម្រូវការចំណាយដែលចេះតែកើនឡើងជាលំដាប់ផង ។ បញ្ហាប្រឈមទាំងអស់នោះ រួមមានដូចខាងក្រោម ÷

*ទី១-* ការធានាអោយបាននូវការគោរពវិន័យថវិកាយ៉ាងខ្ជាប់ខ្ជួន សំដៅកាត់បន្ថយជាអតិបរិមានូវចំណាយមិនបានគ្រោងទុក និង សំដៅបំបាត់ចំណាយក្រៅគម្រោងថវិកា និង ចំណាយដែលមិនចាំបាច់ ដើម្បីសម្រេចបាននូវការគ្រប់គ្រងថវិកាជាតិ ប្រកបដោយប្រសិទ្ធភាព និង ប្រកបដោយភាពជឿទុកចិត្តបាន ។

*ទី២* ការរៀបចំកម្មវិធីចំណូល ចំណាយអោយបានច្បាស់លាស់ ដើម្បីកាត់បន្ថយបំណុលសាច់ប្រាក់កកស្ទះនៅរតនាគារ ដោយអនុវត្តយ៉ាងហ្មឺងម៉ាត់នូវច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ជាពិសេសចៀសវាងនូវការផ្ទេរឥណទានថវិកាដែលនៅសល់ទៅឆ្នាំបន្ទាប់ ព្រមទាំងការចេញអាណត្តិបម្រុងទុក និង ការចេញអាណត្តិច្រើនហួសទៅបង្គរនៅរតនាគារជាតិ ដែលជាប្រការធ្វើឱ្យកើតមានឡើងនូវបំណុលសាច់ប្រាក់ថ្មីទៀត ។

*ទី៣-* បន្តពង្រឹងការគ្រប់គ្រងបំណុល ដោយបន្តអនុវត្តយ៉ាងហ្មឺងម៉ាត់នូវការខ្ចីតែឥណទានដែលមានលក្ខណៈសម្បទាន ។

*ទី៤-* បន្តបង្កើនចំណាយលើវិស័យសង្គមកិច្ច និង សេដ្ឋកិច្ច ជាពិសេសចំពោះវិស័យអាទិភាពទាំងបួនរួមមាន អប់រំ សុខាភិបាល កសិកម្ម និង អភិវឌ្ឍន៍ជនបទ និង ចំណាយវិនិយោគលើប្រព័ន្ធហេដ្ឋា

រចនាសម្ព័ន្ធរូបវន្ត មានផ្លូវ-ស្ពាន និងជាពិសេសចំណាយវិនិយោគលើប្រព័ន្ធស្រោចស្រព ដែលជាអាទិភាពខ្ពស់ផុតរបស់រាជរដ្ឋាភិបាលនៅក្នុងនីតិកាលទី ៣ នៃរដ្ឋសភា ។

**២-៣. គំរោងចំណូល-ចំណាយថវិកាឆ្នាំ ២០០៦**

**ក-គំរោងចំណូលថវិកាក្នុងស្រុក**

១០- តាមការវិភាគ និង ព្យាករណ៍លើស្ថានភាពជាក់ស្តែង ចំណូលថវិកាក្នុងស្រុកក្នុងឆ្នាំ ២០០៥ អាចនឹងសម្រេចបានក្នុងរង្វង់ប្រមាណ ១១,៣៨% នៃផសស ហើយចំណាយសរុបអាចនឹងអនុវត្តបានក្នុងកំរិត ១៦,៨០% នៃផសស ។ លើមូលដ្ឋាននេះ និង ផ្អែកលើការវាយតម្លៃស្ថានភាពសេដ្ឋកិច្ចឆ្នាំ ២០០៦ រាជរដ្ឋាភិបាលកំណត់គោលដៅចំណូលថវិកាក្នុងស្រុកសម្រាប់ឆ្នាំ ២០០៦ អោយសម្រេចបានប្រមាណ ១២% នៃផសស ដែលក្នុងនោះ ចំណូលចរន្តត្រូវសម្រេចបាន ១១,៨១% នៃផសស រួមមានចំណូលសារពើពន្ធ ៩,១៧% នៃផសស និង ចំណូលមិនមែនសារពើពន្ធ ២,៦៤% នៃផសស ។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលកំណត់គោលដៅចំណាយសរុបសំរាប់ឆ្នាំ ២០០៦ អោយសម្រេចបានដល់ ១៧,៥០% នៃផសស ។

១១- ដោយផ្អែកលើតម្រូវការចំណាយ និង គោលដៅនៃការប្រមូលចំណូលសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៦ ដូចមានចែងខាងលើនេះ រាជរដ្ឋាភិបាលត្រូវបន្តអនុវត្តបណ្តាវិធានការហ្មឹងម៉ាត់ទាំងឡាយ ក្នុងការកែទម្រង់ការគ្រប់គ្រងប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ជាពិសេសក្នុងការកៀងគរចំណូល ត្រូវផ្តោតទៅលើបណ្តាវិធានការសំខាន់ៗ មួយចំនួនដូចខាងក្រោម÷

**ទី១- ផ្នែកចំណូលពន្ធដារៈ**

-បន្តការពង្រឹង និង កែលំអរដ្ឋបាលពន្ធដារ ការធ្វើសវនកម្មពន្ធ និង ការកែលំអរចនាសម្ព័ន្ធចាត់តាំង និង គ្រប់គ្រងស្ថាប័ន ជាពិសេសការពង្រីកមូលដ្ឋានយកពន្ធ ដោយធ្វើវិចារណកម្មប្រព័ន្ធលើកទឹកចិត្ត និង ពង្រឹងរដ្ឋបាលពន្ធដារ ។

-អនុវត្តនូវកម្មវិធីកែលំអរចនាសម្ព័ន្ធ តាមរយៈការអនុវត្តន៍នូវប្រព័ន្ធគ្រប់គ្រងតាមបែបអន្តរជាតិចំពោះរាល់តួនាទី ភារកិច្ច និង ប្រតិបត្តិការរបស់នាយកដ្ឋានពន្ធដារ ។

-កសាង និង អនុវត្ត នូវផែនការយុទ្ធសាស្ត្របច្ចេកវិទ្យាពត៌មាន ជាពិសេសខាងផ្នែកប្រមូលពន្ធ ការផ្តល់សេវាជូនអ្នកបង់ពន្ធ ការធ្វើសវនកម្ម និង ការត្រួតពិនិត្យប្រទាក់ក្រឡាគ្នា ។

-អនុម័ត នូវអនុក្រឹត្យសម្រាប់អនុវត្តច្បាប់ស្តីពីវិសោធនកម្មលើច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ។

-អនុវត្តទាំងស្រុង និង ឱ្យបានហ្មឹងម៉ាត់នូវរាល់បទប្បញ្ញត្តិទាំងឡាយនៃច្បាប់ស្តីពីសារពើពន្ធ (ពន្ធដារ) និង វិសោធនកម្មទាំងឡាយនៃច្បាប់នេះ ។

-បន្តអនុវត្តគោលនយោបាយពង្រីកមូលដ្ឋានយកពន្ធ តាមរយៈការពង្រីករបបពិតនៅតាមបណ្តាខេត្ត-ក្រុងផ្សេងទៀត និង បន្តពង្រឹងសវនកម្មលើអ្នកបង់ពន្ធតាមរបបម៉ៅការ ។

- ធ្វើការកែប្រែអនុក្រឹត្យពន្ធលើតំលៃបន្ថែម (VAT) ដើម្បីពង្រីកមូលដ្ឋានប្រមូលពន្ធតាមរបបពិត ។

- បន្តបណ្តុះបណ្តាល និង បង្កើនសមត្ថភាពវិជ្ជាជីវៈ និង សីលធម៌របស់មន្ត្រីពន្ធដារ ដើម្បីពង្រឹងសមត្ថភាពស្ថាប័ន និង រដ្ឋបាលពន្ធដារឱ្យបានរឹងមាំ ក្នុងគោលដៅគ្រប់គ្រងឱ្យបានល្អនូវអ្នកបង់ពន្ធធំ និង មធ្យម ។

- ពង្រឹងលិខិតបទដ្ឋានស្តីពីពន្ធក្នុងវិស័យប្រេងកាត ដើម្បីធានាឱ្យបាននូវការប្រមូលចំណូលជាអតិបរិមាពីវិស័យនេះ តាមរយៈការធ្វើវិសោធនកម្មលើច្បាប់ស្តីពីសារពើពន្ធ (ពន្ធដារ) ។

- ធ្វើការសិក្សាអំពីវិចារណកម្មបន្ត និង លទ្ធភាពវិសោធនកម្មបន្តលើច្បាប់ស្តីពីសារពើពន្ធ (ពន្ធដារ) និង បណ្តាច្បាប់ពាក់ព័ន្ធ ក្នុងគោលដៅបង្កើនចំណូលថវិកាជាតិ ។

- បន្តពង្រឹងអភិបាលកិច្ចរបស់នាយកដ្ឋានពន្ធដារ ។

**ទី២- ផ្នែកចំណូលពន្ធគយៈ**

- ជំរុញការអនុម័តច្បាប់គយ និង ត្រៀមរៀបចំឱ្យបានចប់សព្វគ្រប់នូវលិខិតបទដ្ឋានសម្រាប់អនុវត្តច្បាប់នេះ ។

- បន្តកែលំអនីតិវិធីក្នុងការគ្រប់គ្រងអ្នកនាំទំនិញចេញ- ចូល ដោយតម្រូវឱ្យមានការរៀបចំជាក្រុមហ៊ុននាំចេញ- ចូល និង ក្រុមហ៊ុនជើងសារច្បាស់លាស់ ដើម្បីធានានូវតម្លាភាព និង ភាពងាយស្រួល ក្នុងការត្រួតពិនិត្យ និង ក្នុងការយកពន្ធ និង អាករផ្សេងៗ ។

- ចាប់ផ្តើមអនុវត្តនូវរចនាសម្ព័ន្ធចាត់តាំងថ្មីរបស់ទីចាត់ការគយ និង រដ្ឋាករ ។

- អនុវត្តវិធានការតឹងរឹងក្នុងការបង្កើនចំណូលថវិកា រួមមានៈ

*ក.* វិធានការទប់ស្កាត់ និង បង្ក្រាបអំពើរត់គេចពន្ធ ដោយសហការយ៉ាងជិតស្និទ្ធជាមួយនឹងកងយោធពលខេមរភូមិន្ទ កងកម្លាំងនគរបាល និង អាជ្ញាធរដែនដី ។ គណៈកម្មាធិការបង្ក្រាបអំពើរ រត់ពន្ធត្រូវតែបង្ហាញឱ្យកាន់តែខ្លាំងក្លាឡើងថែមទៀត នូវឋវភាពនៃការងាររបស់ខ្លួនក្នុងការទប់ស្កាត់ និង បង្ក្រាបអំពើររត់គេចពន្ធ ។ ក្នុងការអនុវត្តន៍ភារកិច្ចនេះ ត្រូវយកចិត្តទុកដាក់ជាពិសេស លើវិធានការកែលំអផែនការសកម្មភាពបង្ក្រាបអំពើរត់ពន្ធ ដោយផ្តោតលើមុខទំនិញមួយចំនួនដែលមានវេយិកភាព ដូចជា ប្រេងឥន្ធនៈ មធ្យោបាយដឹកជញ្ជូន បរិក្ខាអេឡិចត្រូនិច និង ការដាក់ចេញនូវនីតិវិធីត្រួតពិនិត្យថ្មី ។

*ខ.* សហការជាមួយនាយកដ្ឋានពន្ធដារក្នុងការចែករំលែក និង ផ្លាស់ប្តូរពត៌មាន រួមទាំងការប្រើប្រាស់មធ្យោបាយអេឡិចត្រូនិចស្តីពីសហគ្រាសធំៗ ដើម្បីពង្រឹងវិន័យ និង ភាពពុកិច្ចពន្ធដារ ។

*គ.* លើកឡើង និង អនុវត្តនូវវិធានការច្បាស់លាស់ តែខន់ក្លន់ លើមុខទំនិញមួយចំនួន ដើម្បីរក្សាប្រភពចំណូល ។

- បន្តអនុវត្តយ៉ាងហ្មឹងម៉ាត់នូវវិធានការពង្រឹងស្ថាប័នគយ និង រដ្ឋាករ មានជាអាទិ៍ៈ បន្តការបណ្តុះបណ្តាល និង ការបង្កើនសមត្ថភាពវិជ្ជាជីវៈ ការបំពាក់ឧបករណ៍ការងារ និង សីលធម៌របស់មន្ត្រីគយ ដើម្បីពង្រឹងសមត្ថភាពស្ថាប័ន និង រដ្ឋបាលគយ ឱ្យបានរឹងមាំ ។

- បន្តការពង្រឹង និង កែលំអរដ្ឋបាលគយ តាមរយៈការធ្វើស្វ័យប្រវត្តិកម្មនីតិវិធីគយ ដើម្បីកែលំអប្រព័ន្ធការងារ បង្កើនប្រសិទ្ធភាពនៃកិច្ចប្រតិបត្តិការ និង លើកកំពស់គុណភាពសេវាកម្មជូនដល់អតិថិជន

ពិសេសគឺត្រូវរៀបចំឱ្យបានសម្រេច ហើយដាក់ឱ្យអនុវត្តសាកល្បងនៅខែ កុម្ភៈ ២០០៦ នូវប្រព័ន្ធបញ្ចរតែមួយ (Single Window) សម្រាប់ត្រួតពិនិត្យការនាំចេញ និង នាំចូល នៅតាមច្រកព្រំដែនមួយចំនួន ពិសេសត្រូវចាប់ផ្តើមនៅកំពង់ផែក្រុងព្រះសីហនុ ។

- ពង្រឹងយន្តការអធិការកិច្ចមុនពេលផ្ទុក ការត្រួតពិនិត្យទំនិញ ការត្រួតពិនិត្យនាវាឆ្លងកាត់ ការបញ្ជូនទំនិញ ការធ្វើអធិការកិច្ចនៅនឹងកន្លែង និង ការប្រមូលចំណូល ។

- បន្តពង្រឹងអភិបាលកិច្ចរបស់រដ្ឋបាលគយ និងរដ្ឋាករ ។

**ទី៣- ចំណូលមិនមែនសារពើពន្ធ:**

- រៀបចំ និង ជម្រុញឱ្យនាយកដ្ឋានចំណូលមិនមែនសារពើពន្ធ បំពេញមុខងាររបស់ខ្លួនបានប្រកបដោយប្រសិទ្ធភាព និង ភាពសក្តិសិទ្ធិ ។

- អនុវត្តឱ្យមានប្រសិទ្ធភាពនូវច្បាប់ និង លិខិតបទដ្ឋានទាំងឡាយពាក់ព័ន្ធនឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ពិសេសបទបញ្ជារបស់នាយករដ្ឋមន្ត្រី លេខ ០២ បប ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០៥ ស្តីពីការពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ។

- កំណត់ឱ្យបានច្បាស់នូវបំណុលពាក់ព័ន្ធចំណូលមិនមែនសារពើពន្ធ ហើយដាក់ចេញនូវផែនការសកម្មភាពជាក់លាក់ ដើម្បីតឹងទារបំណុលទាំងអស់នេះ តាមគ្រប់មុខសញ្ញាទាំងអស់ ។ ក្នុងនេះ ត្រូវផ្តោតការយកចិត្តទុកដាក់ជាពិសេសទៅលើការគ្រប់គ្រងចំណូលពីប្រៃសណីយ៍ និង ទូរគមនាគមន៍ អាកាសចរណ៍ស៊ីវិល ចំណូលពីវិស័យទេសចរណ៍ ចំណូលទិដ្ឋាការ និង ចំណូលពីការជួលរោងចក្រសហគ្រាស និង ទ្រព្យសម្បត្តិរដ្ឋផ្សេងៗទៀត ។

- ត្រៀមរៀបចំបទបញ្ជារបស់រាជរដ្ឋាភិបាលស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ឱ្យបានរួចរាល់ និង អនុវត្តបទបញ្ជានេះឱ្យមានប្រសិទ្ធភាព ។

- ក្រសួង ស្ថាប័នទាំងអស់ ត្រូវប្រគល់ឱ្យក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នូវរាល់កិច្ចសន្យាទាំងអស់ដែលពាក់ព័ន្ធនឹងសម្បទាន ហើយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុត្រូវធ្វើសវនកម្មលើកិច្ចសន្យាធំជាងគេចំនួន ៥ ដើម្បីធានាការពារផលប្រយោជន៍រដ្ឋ និង ពង្រឹងការប្រមូលចំណូលពីកិច្ចសន្យាទាំងអស់នេះ ។

- បញ្ឈប់ការងារធ្វើបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋទាំងអស់ លើកលែងតែសារពើភ័ណ្ឌដីរដ្ឋ ដែលត្រូវបន្តអនុវត្តនៅក្នុងរយៈពេលវែងខាងមុខ ។

- បន្តពង្រឹងការគ្រប់គ្រងចំណូលពីផលទុនប្រៃសណីយ៍ និង ទូរគមនាគមន៍ តាមរយៈការពង្រឹងយន្តការតឹងទារចំណូល ដោយតម្រូវឱ្យក្រុមហ៊ុនទូរស័ព្ទទាំងអស់ បង់ចំណូលដោយត្រង់ទៅក្នុងគណនីរបស់រាជរដ្ឋាភិបាលនៅធនាគារជាតិ ហើយក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ត្រូវសហការជាមួយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្នុងការត្រួតពិនិត្យ និង ផ្ទៀងផ្ទាត់ការបង់ចំណូលនេះ ។

**ខ- គម្រោងចំណាយថវិកា**

១២- ដើម្បីសម្រេចបាននូវគោលដៅដែលបានគូសបញ្ជាក់ខាងលើ គម្រោងចំណាយថវិកាឆ្នាំ ២០០៦ នឹងត្រូវបានរៀបចំឡើងដោយផ្អែកលើបណ្តាមូលដ្ឋានជាយុទ្ធសាស្ត្រដូចខាងក្រោម ÷

• ត្រូវបន្តរិតត្បិតចំណាយសរុបឱ្យស្ថិតក្នុងកំរិត ១៧,៥០% នៃផសស ក្នុងនោះ ចំណាយមូលធន ប្រមាណ ៧,៣០ % នៃផសស ។ ឯចំណាយចរន្តត្រូវស្ថិតក្នុងរង្វង់ ១០,២០% នៃផសស ដើម្បីធានាអតិរេកចរន្តអោយបាន ១,៦១% នៃផសស សំរាប់វិនិយោគ ។ ដោយឡែក ចំណាយមូលធនដោយហិរញ្ញប្បទានក្នុងស្រុកត្រូវកំណត់ក្នុងចំនួន ១,៨៦% នៃផសស ហើយចំណាយមូលធនដោយហិរញ្ញប្បទានក្រៅប្រទេសត្រូវកំណត់ក្នុងចំនួន ៤,៩១% នៃផសស ។ ទន្ទឹមនឹងនេះ បង្កើនចំណាយសំរាប់រំលស់បំណុលដល់ចំនួន ០,៥៣% នៃផសស ។

• ត្រូវបន្តកៀងគរជំនួយផ្លូវការពីបរទេសសំរាប់ការវិនិយោគ (រួមទាំងជំនួយឥតសំណងផង) ដើម្បីទប់ទល់ឱនភាពថវិកាសរុបឱ្យនៅត្រឹម -៥,៥% នៃផសស ។

• ត្រូវបែងចែកចំណាយចរន្តទៅតាមវិស័យនីមួយៗដូចតទៅៈ រដ្ឋបាលទូទៅ ១,៣៦% នៃផសស ផ្នែកសន្តិសុខ និង យោធា ២,០៥% នៃផសស វិស័យសេដ្ឋកិច្ច ១,០៥% នៃផសស និង សង្គមកិច្ចស្មើនឹង ៣,៦៧% នៃផសស ។

១៣- ថវិកាឆ្នាំ ២០០៦ ខាងមុខនេះ ត្រូវបំរើគោលនយោបាយរាជរដ្ឋាភិបាល ក្នុងវិស័យសេដ្ឋកិច្ច និង សង្គមកិច្ច និង ការលើកស្ទួយជីវភាពនៅទីជនបទ សំដៅសំរេចនូវការអភិវឌ្ឍន៍ប្រកបដោយចីរភាព និង ការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ។ ថវិកាឆ្នាំ ២០០៦ នឹងផ្តល់ការបែងចែកជាក់ស្តែងទៅតាមវិស័យជាអាទិភាពទាំងនេះ ដូចខាងក្រោម ÷

• បង្កើនថវិកាសំរាប់វិស័យសុខាភិបាលចំនួន ១៤,៣% ធៀបទៅនឹងថវិកាឆ្នាំ ២០០៥ ដើម្បីសំរេចឱ្យបាននូវសមាមាត្រ ១២,៧៤% នៃចំណាយចរន្តថវិការដ្ឋ ស្របតាមការកំណត់នៃគម្រោងកម្មវិធីចំណាយរយៈពេលមធ្យមសំរាប់វិស័យសុខាភិបាលឆ្នាំ ២០០៦ ។

• បង្កើនថវិកាសំរាប់វិស័យអប់រំចំនួន ២២% ធៀបទៅនឹងថវិកាឆ្នាំ ២០០៥ ដើម្បីសំរេចឱ្យបាននូវសមាមាត្រ ១៨,៤៨% នៃចំណាយចរន្តថវិការដ្ឋ ស្របតាមការកំណត់នៃគម្រោងកម្មវិធីចំណាយរយៈពេលមធ្យមសំរាប់វិស័យអប់រំឆ្នាំ ២០០៦ ។

• បង្កើនថវិកាសម្រាប់ការអភិវឌ្ឍន៍ប្រព័ន្ធស្រោចស្រព ការអភិវឌ្ឍន៍កសិកម្ម និង ការអភិវឌ្ឍន៍ជនបទ ប្រមាណ ៣២% ធៀបទៅនឹងថវិកាឆ្នាំ ២០០៥ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការជំរុញវិស័យសេដ្ឋកិច្ច ដើម្បីកំណើន និង កាត់បន្ថយភាពក្រីក្រ ។

• បង្កើនមូលនិធិថវិកាឃុំ- សង្កាត់ឆ្នាំ ២០០៦ ឱ្យដល់ ៧០ ពាន់លានរៀល (២.៥៤% នៃចំណូលចរន្តថវិការដ្ឋ) ។

## III- និតិវិធី និង បច្ចេកទេសនៃការរៀបចំថវិកាឆ្នាំ ២០០៦

### ក- ការគ្រោងគិតចំណូលថវិកាឆ្នាំ ២០០៦

១៤- ការគ្រោងគិតចំណូលចរន្តរបស់ថវិកា អាស្រ័យលើប្រភពធនធាននៃផលិតផល ឬ ផលទុនដែលជាប្រភពចំណូលសារពើពន្ធ និង មិនមែនសារពើពន្ធ ។ ដោយផ្អែកលើស្ថានភាពសេដ្ឋកិច្ច និង បណ្តា

លក្ខខណ្ឌនៃប្រភពធនធានដូចបានលើកឡើងខាងលើ ក្រសួង ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុង ត្រូវរៀបចំគម្រោងចំណូលថវិការបស់ខ្លួនដូចតទៅ ÷

- ចំណូលសារពើពន្ធត្រូវគិតគូរដោយផ្អែកលើមូលដ្ឋានដូចខាងក្រោម ÷
  - លទ្ធផលដែលទទួលបាននៅក្នុងឆ្នាំកំពុងប្រព្រឹត្តទៅ
  - ផលប៉ះពាល់នៃអតិផរណាមកលើមូលដ្ឋានពន្ធ
  - ការប៉ាន់ស្មានលើការអភិវឌ្ឍន៍សេដ្ឋកិច្ចនៅពេលខាងមុខ
  - ការប្រែប្រួលដែលអាចកើតមានឡើង ព្រមទាំងការត្រួតពិនិត្យ និង ពិចារណាទៅលើអត្រាមូលដ្ឋានប្រមូលពន្ធ និង ការបង្កើតពន្ធថ្មី
  - ចំណូលបន្ថែមដែលសង្ឃឹមថាប្រមូលបាន ដោយសារការពង្រឹង និង កែលំអរដ្ឋបាលពន្ធដាររដ្ឋបាលគយ គោលនយោបាយពន្ធដារ និង គយ និង ការធ្វើវិចារណកម្មសារពើពន្ធ ។
- ចំពោះចំណូលពុំមែនសារពើពន្ធ ត្រូវគិតគូរទៅតាមកិច្ចការដែលនាំឱ្យមានផលទុន ដូចជាកិច្ចសន្យាផ្តល់សេវាកម្ម និង ការពង្រឹង និង កែលំអការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋជាដើម ។ល។

ចំណូលទាំងអស់នេះ ត្រូវផ្អែកលើមូលដ្ឋានតួរលេខស្ថិតិដែលសំរេចបាននៅក្នុងឆ្នាំកន្លងមក និងការ-អភិវឌ្ឍន៍សេដ្ឋកិច្ច ។

## ខ-ការគ្រោងគិតចំណាយថវិកាឆ្នាំ ២០០៦

**១៥-** ការគ្រោងគិតឥណទានថវិកាចំណាយ ត្រូវផ្តើមចេញពីតម្រូវការជាក់ស្តែង និង ដោយផ្ទាល់ដោយផ្អែកទៅលើកត្តាដែលទាក់ទងនឹងចំណាយ ដូចជា តារាងបុគ្គលិក បញ្ជីប៉ាន់ស្មានតំលៃសំភារៈនៃការ-ផ្គត់ផ្គង់ និង ត្រូវផ្អែកទៅតាមធម្មនិយាមចំណាយដែលបានកំណត់កន្លងមក ដូចជា ចំណាយបេសកកម្មចំណាយមធ្យមភាគលើគ្រែមួយរបស់អ្នកជំងឺនៅមន្ទីរពេទ្យ ចំណាយខាងការសិក្សា សំរាប់សិស្ស ឬ និស្សិតម្នាក់ ឬ ត្រូវផ្អែកទៅតាមតួលេខស្ថិតិជាមធ្យមភាគរបស់គណនេយ្យថវិកាសំរាប់ការគ្រប់គ្រងកន្លងមក ។

**១៦-** ជាទូទៅ គម្រោងចំណាយទាំងអស់សម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៦ ត្រូវតែមានការវិភាគយ៉ាងល្អិតល្អន់ និង មានលិខិតយុត្តិការភ្ជាប់មកជាមួយ ដើម្បីពន្យល់តាមជំពូក តាមប្រការ ទៅតាមតារាងគំរូដូចបានធ្លាប់ធ្វើកន្លងមកសម្រាប់ធ្វើជាមូលដ្ឋាននៃការពិភាក្សា ។ ដោយឡែក ចំពោះថវិកាជំពូក ១១ ដែលជាជំពូកប្រមូលផ្តុំលើចំណាយសំភារៈ និង ការគ្រប់គ្រងរដ្ឋបាលចាំបាច់សម្រាប់ដំណើរការរបស់ក្រសួង ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុង ត្រូវតែមានភ្ជាប់មកជាមួយនូវលិខិតយុត្តិការស្របច្បាប់ ដើម្បីឱ្យឃើញនូវមូល-ហេតុនៃតម្រូវការជាក់ស្តែងរបស់បណ្តានាយកដ្ឋាន និង អង្គភាពនៅក្រោមឱវាទ ។ បើប្រៀបធៀបទៅនឹងឆ្នាំ ២០០៥ ចំណាយប្រភេទនេះ ត្រូវតែកាត់បន្ថយចំនួន ៧% ដើម្បីបង្ហាញឱ្យឃើញអំពីភាពហ្មឹងម៉ាត់របស់រាជ-រដ្ឋាភិបាលក្នុងការសន្សំសំចៃថវិកា ទុកសម្រាប់ដោះរំលស់បំណុលសាច់ប្រាក់កកស្ទះនៅរតនាគារជាតិ និងសម្រាប់បង្កើនចំណាយវិនិយោគសាធារណៈ និង ចំណាយលើការថែទាំ និង ជួសជុលហេដ្ឋារចនាសម្ព័ន្ធរូបវន្តពិសេសផ្លូវ ស្ពាន និង ប្រព័ន្ធស្រោចស្រព ។

គ- ការកំណត់កញ្ចប់ថវិកាឆ្នាំ ២០០៦

១៧- រាជរដ្ឋាភិបាលបានធ្វើការកំណត់នូវកញ្ចប់ថវិកាសម្រាប់ក្រសួង-ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុង ដោយផ្អែកលើស្ថានភាពម៉ាក្រូសេដ្ឋកិច្ច គោលនយោបាយសារពើពន្ធ និង គោលនយោបាយថវិកា ហើយដែលកញ្ចប់ថវិកាឆ្នាំ ២០០៦ នេះមិនមានការប្រែប្រួលច្រើនឡើយ បើប្រៀបធៀបនឹងកញ្ចប់ថវិកាឆ្នាំ ២០០៥ ។ ជារួម ចំណាយចរន្តនៃថវិកាឆ្នាំ ២០០៦ ត្រូវបានបែងចែកតាមគោលដៅដូចខាងក្រោម ៖

- ការបង្កើនចំណាយសម្រាប់ពង្រឹងសមត្ថភាពរដ្ឋបាល បច្ចេកទេស និង ហិរញ្ញវត្ថុរបស់ក្រុមប្រឹក្សាឃុំ- សង្កាត់ ក្នុងគោលដៅជម្រុញការអភិវឌ្ឍន៍មូលដ្ឋាន
- ការបង្កើនចំណាយសម្រាប់ក្រសួងអាទិភាពទាំងបួន និង ធនធានទឹក
- ការត្រៀមឥណទានថវិកាសម្រាប់សងបំណុលសំខាន់ៗមួយចំនួន ។

១៨- ដូច្នេះ កញ្ចប់ថវិកានេះ គឺជាលទ្ធភាពថវិកាខ្ពស់បំផុតនៃគម្រោងចំណាយចរន្ត សម្រាប់ផ្តល់ជូនក្រសួង ស្ថាប័ន និង មន្ទីរជំនាញតាមខេត្ត- ក្រុងនីមួយៗ ធ្វើការបែងចែកលម្អិតទៅតាមជំពូក ប្រការ កថាខ័ណ្ឌ និង អនុកថាខ័ណ្ឌ នៃមាតិកាថវិកា និង ដោយផ្អែកលើកម្មវិធីសកម្មភាព និង ផែនអាទិភាពរបស់ខ្លួនសម្រាប់ឆ្នាំ ២០០៦ ដើម្បីឱ្យបានស្របតាមតម្រូវការប្រើប្រាស់ជាក់ស្តែង ។ ដូចជាឆ្នាំមុនៗដែរ ក្នុងរយៈពេលអនុវត្តថវិកានៃត្រីមាសទី ១ ឆ្នាំ ២០០៦ នេះ នឹងមិនមានការអនុញ្ញាតឱ្យធ្វើនិយ័តភាពផ្ទៃក្នុងថវិការបស់ក្រសួង ស្ថាប័ន និង មន្ទីរជំនាញនៅតាមខេត្ត- ក្រុងទេ ។

១៩- ប្រការសំខាន់ៗដែលត្រូវយកចិត្តទុកដាក់ក្នុងការបែងចែកកញ្ចប់ថវិកាឆ្នាំ ២០០៦ នេះ មានដូចតទៅ ៖

ក- ចំណាយបៀវត្ស ត្រូវគ្រោងគិតទៅតាមតារាងប្រព័ន្ធប្រាក់បៀវត្សថ្មីនៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាលសាធារណៈ និង តាមចំនួនមន្ត្រីរាជការដែលមានជាក់ស្តែងក្នុងឆ្នាំ ២០០៥ ។ ចំនួនមន្ត្រីរាជការដែលលើស ត្រូវមានសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល ដោយផ្អែកតាមសំណើរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និង មានទិដ្ឋាការរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។ ចំនួនមន្ត្រីរាជការដែលចូលនិវត្តន៍ ផ្ទេរចេញ ឬ លាឈប់ពីក្របខ័ណ្ឌរដ្ឋ និង មរណៈភាព ត្រូវកាត់ចេញពីអង្គភាពរបស់ខ្លួន ។ ប្រសិនបើមានការតម្លើងឋានៈ ឬ មានមន្ត្រីថ្មី ត្រូវគ្រោងដោយឡែកនៅក្នុងថវិកាសរុបនៅក្នុងជំពូក ១០ ។ ក្រសួង ស្ថាប័ន និង មន្ទីរជំនាញខេត្ត- ក្រុង មិនត្រូវគិតនូវអតិផរណានៅក្នុងចំណាយថវិកាជំពូក ១០ នេះទេ ។ ចំពោះបុគ្គលិកអណ្តែត និង ភ្នាក់ងារជាតិជាប់កិច្ចសន្យា រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈត្រូវស្នើសុំការធានាចំណាយថវិកាពីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុជាមុន មុននឹងចេញលិខិតអនុញ្ញាតឱ្យក្រសួង ស្ថាប័ន និង មន្ទីរជំនាញខេត្ត- ក្រុង ជ្រើសរើស និង ប្រើប្រាស់ ។ នៅឆ្នាំ ២០០៦ ខាងមុខនេះ រាជរដ្ឋាភិបាលនឹងបង្កើនប្រាក់បៀវត្សមូលដ្ឋានចំនួន ១៥ ភាគរយ ដែលនឹងប្រើឥណទាននៃមូលនិធិបម្រុង ។

ខ- ចំណាយដំណើរការរដ្ឋបាល ទិញសំភារៈ និង ការជួសជុលតូច ត្រូវតែគ្រោងទុកប្រកបដោយលក្ខណៈស៊ិតគៀត សន្សំសំចៃ និង ត្រូវពឹងផ្អែកទៅតាមកម្មវិធីសកម្មភាព និង ធម្មនិយាមដូចមានចែងខាង

លើ ដើម្បីតម្រឹមឱ្យនៅក្នុងកញ្ចប់ថវិកានេះ ។ ត្រូវយកចិត្តទុកដាក់គិតគូរសោហ៊ុយចំណាយជាអចិន្ត្រៃយ៍ ដូចជា ទូរស័ព្ទ អគ្គិសនី ទឹក សំភារៈការិយាល័យ ប្រេងឥន្ធនៈ ការទទួលភ្ញៀវ ដើម្បីគ្រប់គ្រងចំណាយទាំងនេះនៅក្នុងល័ក្ខខ័ណ្ឌសន្សំសំចៃបំផុត ។ នៅពេលអនុវត្តថវិកា ហាមដាច់ខាតមិនអោយមានចំណាយលើសពីឥណទានថវិកា ដែលបានគ្រោងសំរាប់មុខសញ្ញានេះ និង ហាមដាច់ខាតមិនឱ្យមានការជំពាក់បំណុលដោយខ្ចីទំនិញ ឬ សេវាមកប្រើប្រាស់នៅក្រៅបរិបថនៃថវិកាទេ ។

ត- កន្លងមកចំណាយសម្រាប់មុខសញ្ញាអគ្គិសនី ទូរស័ព្ទ ទឹក ប្រេងឥន្ធនៈ និង ការទទួលភ្ញៀវមានលក្ខណៈខ្ជះខ្ជាយ ។ ចំណាយសម្រាប់មុខសញ្ញាទាំងនេះចេះតែកើនឡើង ហើយការទូទាត់មិនបានទាន់ពេលវេលា ដែលនាំអោយមានបំណុលកកស្ទះពីមួយឆ្នាំទៅមួយឆ្នាំ ។ ដើម្បីដោះស្រាយបញ្ហានេះ ចំពោះចំណាយអគ្គិសនី ទូរស័ព្ទ និង ទឹក ត្រូវអនុវត្តនូវវិធានការដូចខាងក្រោម៖

- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រសួង ស្ថាប័នទាំងអស់ ត្រូវសហការត្រួតពិនិត្យលើការប្រើប្រាស់បច្ចុប្បន្ន ដើម្បីរៀបចំយន្តការ និង ប្រព័ន្ធគ្រប់គ្រងការប្រើប្រាស់អគ្គិសនី ទូរស័ព្ទ និង ទឹក អោយបានត្រឹមត្រូវ ម៉ត់ចត់ និង ប្រកបដោយប្រសិទ្ធភាព ។ ក្នុងករណីរកឃើញការលួចបន្តចរន្តអគ្គិសនី ទូរស័ព្ទ និង ទឹក ប្រើបាស់ផ្ទាល់ខ្លួនខុសមុខសញ្ញា របស់ក្រសួង ស្ថាប័នណាមួយ រដ្ឋមន្ត្រីក្រសួងនោះជាអ្នកទទួលខុសត្រូវចំពោះមុខនាយករដ្ឋមន្ត្រី និង ចំពោះមុខស្ថាប័ននីតិបញ្ញត្តិ ។ អគ្គិសនីកម្ពុជា រដ្ឋាករទឹកស្វយ័ត និង ក្រុមហ៊ុនទូរស័ព្ទ ត្រូវកាត់ផ្តាច់បណ្តាញលួចលាក់ទាំងនោះភ្លាម ហើយធ្វើរបាយការណ៍ជូនក្រសួងអាណាព្យាបាលបច្ចេកទេស និង ក្រសួងអាណាព្យាបាលហិរញ្ញវត្ថុ និង ចំលងជូនទីស្តីការគណៈរដ្ឋមន្ត្រី ។

- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រសួង ស្ថាប័នទាំងអស់ ត្រូវសហការគ្រោងឥណទានសំរាប់អគ្គិសនី ទូរស័ព្ទ និង ទឹក ប្រកបដោយភាពសន្សំសំចៃខ្ពស់ ដោយយកចំណាយជាក់ស្តែងពីឆ្នាំមុនធ្វើជាពិដាន ហើយកាត់បន្ថយចំណាយមុខសញ្ញានេះអោយចុះមកនៅក្នុងកំរិតមួយសមស្រប តាមការចាំបាច់ពិតប្រាកដរបស់ក្រសួងស្ថាប័ន ។

- ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ អគ្គិសនីកម្ពុជា រដ្ឋាករទឹកស្វយ័ត និង ក្រុមហ៊ុនផ្តល់សេវាទូរស័ព្ទ ត្រូវផ្តល់វិក័យប័ត្រប្រចាំខែនីមួយៗ អោយបានមុនថ្ងៃទី ១៥ នៃខែបន្ទាប់ ។ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវធ្វើការទូទាត់ថ្លៃប្រើប្រាស់អគ្គិសនី ទូរស័ព្ទ និង ទឹក ដោយត្រង់ ទៅអ្នកផ្គត់ផ្គង់ ដោយផ្អែកលើវិក័យប័ត្រប្រើប្រាស់ជាក់ស្តែងប្រចាំខែ ដែលចេញ ដោយអ្នកផ្គត់ផ្គង់ និង ក្រោយពីត្រូវបានផ្ទៀងផ្ទាត់ និង ការឯកភាពទទួលស្គាល់ដោយក្រសួង ស្ថាប័ន ដែលបានប្រើប្រាស់ ។ ក្នុងការអនុវត្តន៍ថវិកាឆ្នាំ ២០០៦ ខាងមុខនេះ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នឹងធ្វើការទូទាត់នៅក្នុងខែមករា ២០០៦ នៃវិក័យប័ត្រប្រើប្រាស់ប្រចាំខែ ធ្នូ ២០០៥ និង វិក័យប័ត្រប្រើប្រាស់ប្រចាំខែពីខែមករា ដល់ ខែ វិច្ឆិកា ២០០៦ ។ រីឯវិក័យប័ត្រប្រើប្រាស់ក្នុងខែធ្នូ ២០០៦ នឹងធ្វើការទូទាត់នៅក្នុងខែមករា ឆ្នាំ ២០០៧ ។ ចំពោះបំណុលមុនខែធ្នូ ២០០៥ ក្រសួងស្ថាប័នទាំងអស់ត្រូវទទួលទូទាត់ជំរះបញ្ជីរៀងៗខ្លួន ដោយប្រើឥណទានជំពូក ១១ តាមច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៥ ។ ហាមដាច់ខាតមិនអោយមានការពន្យាការទូទាត់លើមុខសញ្ញាចំណាយនេះ ដោយយកឥណទាននេះទៅប្រើប្រាស់លើមុខសញ្ញាផ្សេង ហើយផ្ទេរបន្ទុកនេះមកលើថវិការួមទេ ។

- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវស្នើឡើងនូវវិធានការជាក់លាក់ ក្នុងការត្រួតពិនិត្យ និង គ្រប់គ្រង ការប្រើប្រាស់អគ្គិសនី ទូរស័ព្ទ និង ទឹក ដើម្បីជូនឱ្យប្រមុខនៃរាជរដ្ឋាភិបាលពិនិត្យ និង សម្រេច ហើយដាក់ឱ្យគ្រប់ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល អនុវត្តឱ្យបានខ្ជាប់ខ្ជួន និង ហ្មឹងម៉ាត់បំផុត ។ ដោយឡែក ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវរៀបចំសេចក្តីព្រាងវិសោធនកម្មលើអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី ១៦ វិច្ឆិកា ១៩៩៩ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋនៅតាមក្រសួង ខេត្ត-ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និង អង្គភាពសាធារណៈរដ្ឋបាល និង អនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ វិច្ឆិកា ១៩៩៩ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ ដើម្បីគ្រប់គ្រងតាមការណែនាំនេះ ។

- ក្នុងខណៈដែលប្រេងឥន្ធនៈកំពុងឡើងថ្លៃ គំរោងចំណាយប្រេងឥន្ធនៈសំរាប់ឆ្នាំ ២០០៦ ត្រូវកាត់បន្ថយចំនួន ១០% ធៀបនឹងឥណទានសំរាប់ចំណាយប្រេងឥន្ធនៈក្នុងឆ្នាំ ២០០៥ ដើម្បីអនុវត្តវិធានការសន្សំសំចៃថាមពលថ្នាក់ជាតិផង និង ដើម្បីត្រៀមបង្វែរចំណាយនេះ សំរាប់ចំណាយជាយថាហេតុនៃគ្រោះធម្មជាតិផង ។

ឃ- ចំពោះចំណាយជំពូកផ្សេងៗទៀត ត្រូវគ្រោងទៅតាមការចាំបាច់ និង ត្រូវស្ថិតនៅក្នុងកញ្ចប់ថវិការួមដែលបានបែងចែកជូននេះដែរ ។

២០- កញ្ចប់ថវិកា គឺជាកម្មវត្ថុនៃការពិភាក្សានៅក្នុងកិច្ចប្រជុំការពារថវិការបស់ក្រសួង ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុង ។ ការពិភាក្សាថវិកានេះ គឺគ្រាន់តែជាការពិភាក្សាបែងចែកថវិកា ទៅតាមជំពូកតែប៉ុណ្ណោះ ។ ដូច្នេះ ក្រសួង ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុង ត្រូវកសាងគម្រោងថវិកាមិនឱ្យលើសតួលេខនៃកញ្ចប់ថវិកានេះទេ ។ ក្រសួង ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុងណាមួយ ដែលបានកសាងគម្រោងលើសកញ្ចប់ថវិកានេះ នឹងត្រូវកាត់ចេញនូវចំនួនដែលលើសនោះ មុននឹងចាប់ផ្តើមធ្វើការពិភាក្សា ។ ចំពោះ ក្រសួងអាទិភាពទាំងបួន ដែលមានកម្មវិធីអភិវឌ្ឍន៍ស្រុកឈានមុខ (ADD) និង កម្មវិធីសកម្មភាពជាអាទិភាព (PAP) ការពិភាក្សាលើគម្រោងចំណាយនេះ ត្រូវធ្វើឡើងដោយឡែកដោយផ្អែកលើកម្មវិធីជាក់ស្តែងទាំងនេះ ។ ចំណាយសម្រាប់កម្មវិធីអភិវឌ្ឍន៍ស្រុកឈានមុខ (ADD) ត្រូវកត់ត្រាចូលក្នុងជំពូក ១៣.០១ ។ រីឯចំណាយសម្រាប់កម្មវិធីសកម្មភាពជាអាទិភាព (PAP) ត្រូវកត់ត្រាចូលក្នុងជំពូក ១៣.០២ ។ ចំពោះកញ្ចប់ថវិការបស់ក្រសួង ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុង ត្រូវបានកំណត់នៅក្នុងលិខិតដែលមានភ្ជាប់មកជាមួយនេះ ។

**ឃ- ការរៀបចំ និង ការវិភាគសំណើនានា**

២១- ថវិកាកំពុងប្រព្រឹត្តទៅឆ្នាំ (n-1) ឆ្នាំ ២០០៥ តាមច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម នស/រកម/១២០៤ /០០២ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៤ ត្រូវធ្វើជាមូលដ្ឋាននៃការរៀបចំថវិកាឆ្នាំ ២០០៦ ឆ្នាំ (n) ដើម្បីធានាឱ្យសេវាសាធារណៈនានាអាចដំណើរការទៅបាន ។ ក្រសួង ស្ថាប័ន ត្រូវតែផ្អែកលើថវិកានៃឆ្នាំកំពុងប្រព្រឹត្តទៅ និង ការណែនាំទាំងឡាយខាងលើនេះ សម្រាប់ធ្វើជាមូលដ្ឋាន ដោយគ្រាន់តែសម្រួលទៅតាមតម្រូវការចាំបាច់ដែលទាក់ទងទៅនឹងបណ្តាមូលហេតុដូចខាងក្រោម ÷

- ចលនាឥណទានដែលបានធ្វើឡើងក្នុងឆ្នាំកំពុងប្រព្រឹត្តដូចជា:
  - ការបង្វែរឥណទានថវិកាផ្ទៃក្នុងជំពូក ឬ ពីជំពូកមួយទៅជំពូកមួយទៀត ដែលធ្វើឱ្យការបែងចែកឥណទានដើមនៃក្រសួង ស្ថាប័ន ព្រមទាំងមន្ទីរជំនាញខេត្ត-ក្រុងមានការប្រែប្រួល ។
  - ការផ្ទេរឥណទានថវិកាបន្ថែមសម្រាប់ផលប្រយោជន៍របស់ក្រសួង ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុង ។
- ផលប៉ះពាល់ជាយថាហេតុនៃអតិផរណានៅក្នុងឆ្នាំទៅលើថ្លៃនៃផលិតផលចាំបាច់ ដូចជា អគ្គិសនី ទឹក ប្រេងឥន្ធនៈ សោហ៊ុយដឹកជញ្ជូន និង ចំណាយរដ្ឋបាល ។ ល ។

២២- គម្រោងថវិការបស់ក្រសួង ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុង ត្រូវតែបញ្ជាក់នូវមូលហេតុច្បាស់លាស់ ដូចមានចែងខាងលើនេះ ហើយរាល់សំណើបន្ថែម ត្រូវតែមានការពន្យល់បញ្ជាក់ភ្ជាប់មកជាមួយនូវរាល់កង្វះខាតឥណទានថវិកានៅក្នុងឆ្នាំកំពុងប្រព្រឹត្តទៅ ដែលអាចយកមកពិភាក្សាបាន លុះត្រាតែមាននៅក្នុងក្របខ័ណ្ឌកម្មវិធីសកម្មភាពនៃឆ្នាំផែនការ ។

២៣- ឥណទានថវិកាដែលបានគិតគូរដោយផ្អែកលើមូលដ្ឋានខាងលើនេះ នឹងមានការប្រែប្រួលអាស្រ័យដោយមានការពង្រីកសកម្មភាពនៃឆ្នាំកំពុងប្រព្រឹត្តទៅ ឬ មានកម្មវិធីសកម្មភាពថ្មី ដែលត្រូវចាប់ផ្តើមអនុវត្តនៅក្នុងឆ្នាំនៃផែនការ ។

២៤- បច្ចេកទេសវិភាគដ៏ទៃទៀតគឺ យកចំណាយថវិកាឆ្នាំមុន ដូចជា ចំណាយដំណើរការរដ្ឋបាលសម្រាប់មន្ត្រីរាជការម្នាក់ៗ ទ្រង់ទ្រាយនៃចំណាយ ប្រភពនៃចំណាយ និង អត្ថប្រយោជន៍នៃចំណាយចាំបាច់មួយចំនួន សម្រាប់ធ្វើជាមូលដ្ឋានគ្រោងគិតសម្រាប់ឆ្នាំផែនការ ។

២៥- ជាសរុប ឥណទានថវិកាចាំបាច់របស់ក្រសួង ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុងនីមួយៗ ត្រូវតែបម្រើទៅលើ :

- គោលដៅរបស់ក្រសួង ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុងនីមួយៗ
- បណ្តាសកម្មភាពជាអាទិភាពរបស់ខ្លួន ដែលបានកំណត់ច្បាស់លាស់
- កម្មវិធីដែលត្រូវចាប់ផ្តើមអនុវត្ត
- មធ្យោបាយដំណើរការ
- និង វិធានការនៃការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពខ្ពស់ ។

## IV- សេចក្តីសន្និដ្ឋាន

២៦- រាជរដ្ឋាភិបាលមានឆន្ទៈដាច់ខាតក្នុងការបន្តនូវកំណែទម្រង់គ្រប់វិស័យ ពិសេសគឺការពង្រឹងអភិបាលកិច្ចល្អក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ នៅក្នុងស្មារតីនេះ រាជរដ្ឋាភិបាលតម្រូវឱ្យគ្រប់ក្រសួង ស្ថាប័នទាំងអស់ អនុវត្តយ៉ាងហ្មឹងម៉ាត់ និង ម៉ត់ចត់បំផុត នូវបទបញ្ញត្តិទាំងឡាយនៃអនុក្រឹត្យលេខ ៦០

អនុក្រ.បក ចុះថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ ១៩៩៥ ស្តីពីការគ្រប់គ្រងលទ្ធកម្មសាធារណៈ និង ប្រកាសស្តីពីការធ្វើវិសហមជ្ឈការលទ្ធកម្មសាធារណៈ សម្រាប់ចំណាយក្នុងជំពូក ១១ និង ជំពូក ១៣ នៃថវិកាជាតិ ព្រមទាំងជំពូក ៥០.០១ ចំពោះគំរោងដែលអនុវត្តដោយឯកជន ដោយលើកលែងតែចំណាយពិសេសខ្លះរបស់ព្រះបរមរាជវាំងតែប៉ុណ្ណោះ ។ ដើម្បីធានាឱ្យបាននូវភាពស័ក្តិសិទ្ធិ និង ប្រសិទ្ធភាពក្នុងការអនុវត្តន៍ចំណាយថវិកាជាតិជាពិសេស ដើម្បីជៀសវាងបញ្ហាកកស្ទះសាច់ប្រាក់ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នឹងបន្តសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ ដើម្បីរៀបចំឱ្យបានត្រឹមត្រូវនូវកម្មវិធីដេញថ្លៃជាសាធារណៈ និង ផែនការតម្រូវការសាច់ប្រាក់របស់ក្រសួង ស្ថាប័ននីមួយៗ សំរាប់ធានាទូទាត់កិច្ចសន្យាទាំងអស់នេះជាដំណាក់ៗ នៅក្នុងឆ្នាំថវិកានីមួយៗ ។

២៧- ពេលទទួលសារាចរណែនាំនេះ គ្រប់ក្រសួង ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុង ត្រូវរៀបចំជាបន្ទាន់ នូវគម្រោងចំណូល- ចំណាយថវិការបស់ខ្លួន សម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៦ ទៅតាមតារាងគំរូដែលភ្ជាប់មកជាមួយនេះ ហើយផ្ញើរមកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ (នាយកដ្ឋានថវិកា) ចំនួនពីរច្បាប់យ៉ាងយូរបំផុត ត្រឹមថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០០៥ ពីព្រោះការពិភាក្សា នឹងត្រូវចាប់ផ្តើមនៅថ្ងៃទី ០១ ខែ សីហា ដល់ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០០៥ នេះតទៅ ។ តួរលេខគំរោងចំណូល- ចំណាយថវិកា ត្រូវសរសេរជាលេខអន្តរជាតិ (1.2.3) ហើយឯកតាទាបបំផុតគិតត្រឹម 0.1 លានរៀល ។

២៨- ក្នុងការអនុវត្តន៍សារាចរណែនាំនេះ បើក្រសួង ស្ថាប័ន និង មន្ទីជំនាញខេត្ត-ក្រុង មានចំណុចណាមួយមិនច្បាស់លាស់ខាងផ្នែកបច្ចេកទេស ត្រូវទាក់ទងជាបន្ទាន់ ជាមួយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ (នាយកដ្ឋានថវិកា ) ។

ធ្វើនៅភ្នំពេញ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ ២០០៥

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា

"***ដើម្បីជូនជ្រាប***"

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័ន
- គ្រប់អភិបាលខេត្ត-ក្រុង
- គ្រប់មន្ទីរជំនាញខេត្ត-ក្រុង

"***ដើម្បីអនុវត្ត***"

- ឯកសារ-កាលប្បវត្តិ